នាយកវិទ្យាល័យ សម្តេចឪ សម្តេចម៉ែ មានភារកិច្ចរៀង ។ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ១៦៣ អយក.ប្រក**

**ស្តីពីប្តូរឈ្មោះសាលាបឋមសិក្សាពោធិ៍ចន្ទ**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤ ។
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ។
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥-១០-១៩៨៦ ស្តីពីការកំណត់បទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌសំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំយុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លេខ ៩០-៩៥ ចុះថ្ងៃទី ១៤-១០-៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១ :** អនុញ្ញាតអោយការិយាល័យអប់រំយុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្តូរឈ្មោះសាលាបឋមសិក្សាពោធិវង្ស នៅភូមិពោធិវង្ស ឃុំថ្កូវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មកជា « **សាលាបឋមសិក្សា សម្តេចម៉ែ ពោធិវង្ស**» ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ នេះតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រធានមន្ទីរ ក្រសួងអប់រំយុវជន និង កីឡា ប្រធាននាយកដ្ឋាន ចាត់តាំង ប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ព្រៃវែង នាយកសាលាបឋមសិក្សាសម្តេចម៉ែ-ពោធិវង្ស មានភារកិច្ច អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តូល ឡោះ**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

## ប្រកាសលេខ ០៦៤ អយក.ប្រក

## ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្មោង

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា